ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅថវិកាពលរដ្ឋ
# ឆ្នាំ២០២៤

**នាយកដ្ឋានហិរញ្ញវត្ថុ**
**ខែមីនា ឆ្នាំ២០២៤**

# មាតិកា


១. សេចក្ដីផ្ដើម ........ 1
២. ពាក្យគន្លឹះ ........ 2
៣. ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ........ 5
៤. របនាសម្ព័ន្ធថវិកាកម្មវិធី ........ 6
៤.១. គោលបំណងគោលនយោបាយ ........ 6
៤.២. ការរៀបចំកម្មវិធី ........ 6
៤.៣. ការរៀបចំអង្គភាពថវិកា ........ 8
៥. ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ ២០២៤ ........ 9
៥.១. ស្ថានភាពចំណូល ........ 9
៥.២. ស្ថានភាពចំណាយរបស់ក្រសួងក្នុងឆ្នាំ២០២៤ ........ 10
៥.២.១. ស្ថានភាពចំណាយរបស់ក្រសួង ........ 11
៥.២.២. ថវិការបស់អង្គភាពរដ្ឋបាលកណ្ដាល ........ 19
៥.២.៣. ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ........ 21
៥.២.៤. ការផ្ទេរថវិកា ពាមុខងារឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ........ 22
៥.៣. មុខសញ្ញាចំណាយសំខាន់ៗរបស់ក្រសួង ........ 24
៥.៣.១. ថវិកាបន្ទុកបុគ្គលិក ........ 26
៥.៣.២. ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ ........ 27
៥.៣.៣. ថវិកាអាហារូបករណ៍សិស្សក្រីក្រ ........ 28
៥.៣.៤. កម្មវិធីផ្ដល់អាហារតាមសាលារៀន ........ 29
៥.៣.៥. ថវិកាមត្តេយ្យសិក្សាសហគមន៍ ........ 30
៥.៣.៦. ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ........ 32
៥.៣.៧. ការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ........ 33
៥.៣.៨. ការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ........ 34
៥.៣.៩. ការអភិវឌ្ឍយុវជន ........ 35
៦. សូចនាករសមិទ្ធកម្ម និងគោលដៅ ........ 36
៧. ឯកសារយោង ........ 39

# បញ្ជីរូបភាព


រូបភាពទី 1 កម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា....................................7

រូបភាពទី 2 អង្គភាពថវិកាឆ្នាំ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ..........9

រូបភាពទី 3 ចំណូលរបស់ក្រសួងអប់រំ យុវជន និងកីឡា ..................................9

រូបភាពទី 4 ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា.................................... 11

រូបភាពទី 5 ថវិកាចំណាយចរន្តឆ្នាំ ធៀបនឹងចំណាយចរន្តថ្នាក់ជាតិ ...................... 12

រូបភាពទី 6 ចំណាយបន្ទុកបុគ្គលិក និងក្រៅបន្ទុកបុគ្គលិក ............................. 13

រូបភាពទី 7 ថវិការបស់រដ្ឋបាលកណ្ដាល មន្ទីររាជធានី-ខេត្ត និងផ្ទេរពាមុខងារ ... 14

រូបភាពទី 8 ថវិការបស់រដ្ឋបាលកណ្ដាលឆ្នាំ ................................................ 19

រូបភាពទី 9 ថវិកាតាមកម្មវិធីរបស់រដ្ឋបាលកណ្ដាល ....................................20

រូបភាពទី 10 ថវិការបស់មន្ទីររាជធានី-ខេត្ត .................................................21

រូបភាពទី 11 កាផ្ទេរពាមុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ.................................22

រូបភាពទី 12 កាផ្ទេរពាមុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមមន្ទីររាជធានី-ខេត្ត.23

រូបភាពទី 13 ថវិកាបន្ទុកបុគ្គលិក .........................................................26

រូបភាពទី 14 ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ .......................27

រូបភាពទី 15 ថវិកាអាហារូបករណ៍សិស្សក្រីក្រ..........................................28

រូបភាពទី 16 ថវិកាកម្មវិធីស្បៀងអាហារតាមសាលារៀន ................................30

រូបភាពទី 17 ថវិកាមត្តេយ្យសិក្សាសហគមន៍ ...........................................31

រូបភាពទី 18 លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ......................32

រូបភាពទី 19 ចំនួនមេដាយដែលកម្ពុជាទទួលបានក្នុងព្រឹត្តិការណ៍ស៊ីហ្គេម ........33

រូបភាពទី 20 ចំនួនមេដាយដែលកម្ពុជាទទួលបានក្នុងព្រឹត្តិការណ៍អាស៊ានប៉ារ៉ាហ្គេម..34

រូបភាពទី 21 ចំនួនយុវជន និងកុមារទទួលបានបណ្តុះបណ្តាលបំណិនសតវត្សរ៍ទី២១..35

# ១. សេចក្តីផ្តើម

វិស័យអប់រំជាកត្តាអាទិភាពដែលអាចជំរុញឱ្យប្រទេសជាតិមួយឈានទៅរកការអភិវឌ្ឍប្រកបដោយចីរភាព កម្ពុជាជាប្រទេសដែលទើបនឹងងើបចេញពីរបបខ្មៅងងឹតដែលគ្រប់វិស័យទ្រទ្រង់ជាតិទាំងអស់ត្រូវបានបំផ្លិចបំផ្លាញជាពិសេសគឺវិស័យអប់រំ។ គោលការណ៍ដាក់ឱ្យអនុវត្តន៍ដំបូងរបស់វិស័យអប់រំគឺអ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ ពោលគឺគ្រូបង្រៀនមិនមានចំណេះដឹងខ្ពង់ខ្ពស់និងមិនមានគរុកោសល្យពេញលេញ នាពេលនោះសៀវភៅសិក្សានិងកម្មវិធីសិក្សាត្រូវបានតាក់តែងនិងរៀបចំសារជាថ្មីទាំងស្រុង រីឯការកសាងរចនាសម្ព័ន្ធប្រព័ន្ធអប់រំជាថ្មីត្រូវធ្វើឡើងជាបន្តបន្ទាប់ចាប់តាំងពីពេលនោះមក។

ក្រសួងអប់រំ យុវជន និងកីឡានៅតែបន្តធ្វើការងារយ៉ាងសកម្ម ដោយបានក្លាយទៅជាទម្លាប់នៃការអនុវត្តការដ្ឋានកំណែទម្រង់យុទ្ធសាស្ត្រវិស័យអប់រំផតឈប់ឈរ ឆ្ពោះទៅមុខជានិច្ចប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលថ្មីនីតិកាលទី៧ ជាពិសេស បញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស ក្នុងនោះការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់សុខភាពនិងសុខុមាលភាពប្រជាជន ការពង្រឹងប្រព័ន្ធគាំពារសង្គមនិងប្រព័ន្ធស្បៀង ព្រមទាំងការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

សៀវភៅថវិកាពលរដ្ឋនេះ បានបង្កើតឡើងសម្រាប់លើកកម្ពស់ចំណេះដឹងផ្នែកថវិកាដែលត្រូវបានរៀបចំឡើង ដើម្បីឱ្យពលរដ្ឋភាគច្រើន មានលទ្ធភាពយល់ដឹងអំពីព័ត៌មានថវិកាជាតិដែលក្រសួងអប់រំ យុវជន និងកីឡាបានប្រើប្រាស់ព្រមទាំងផ្តល់នូវព័ត៌មានសង្ខេប ងាយយល់ ដោយរៀបចំទិន្នន័យថវិការដ្ឋឱ្យសមស្របទៅតាមបរិបទ និងប្រើប្រាស់វិធីសាស្ត្រសាមញ្ញៗ។

## ២. ពាក្យគន្លឹះ

| ពាក្យគន្លឹះ | បរិយាយ |
|---|---|
| កម្មវិធី | សំដៅដល់ការប្រមូលផ្តុំនូវតំណាងទាននៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលរាជធានី ខេត្ត ក្រុង/ស្រុក/ខណ្ឌ ដែលរួមចំណែកដល់ការអនុវត្ត គោលនយោបាយសាធារណៈដែលស្ថិតក្រោមការគ្រប់គ្រង របស់ខ្លួន។ កម្មវិធីនីមួយៗមានគោលបំណងច្បាស់លាស់ ដែលអាចវាស់វែងបាន ដោយមានការកំណត់សូចនាករ ជាក់លាក់។ ជាទូទៅ ក្រសួង ស្ថាប័នមួយអាចមានកម្មវិធី ជាមធ្យមចំនួន៥។ កម្មវិធី ជាមូលដ្ឋានសម្រាប់កំណត់ អនុកម្មវិធី និងចង្កោមសកម្មភាព។ |
| ផ.ផ.ស | ផលិតផលក្នុងស្រុកសរុប គឺជាសូចនាករសេដ្ឋកិច្ចមួយ ដែលវាស់វែងអំពី ទ្រព្យសម្បត្តិរបស់ប្រជាជាតិមួយ ឬជាអ្វីៗ ដែលត្រូវបានផលិតឡើង ក្នុងប្រទេសមួយ ក្នុងរយៈពេល មួយឆ្នាំ។ |
| ចំណាយចរន្ត | មូលនិធិដែលត្រូវបានប្រើប្រាស់ជាប្រចាំ ដើម្បីទ្រទ្រង់កិច្ច ប្រតិបត្តិការផ្នែករដ្ឋបាល។ ចំណាយចរន្តរួមមាន៖ ចំណាយបន្ទុកបុគ្គលិក និងចំណាយក្រៅបន្ទុកបុគ្គលិក។ |
| ចំណាយមូលធន | មូលនិធិដែលត្រូវបានប្រើប្រាស់សម្រាប់វិនិយោគក្នុងកិច្ច អភិវឌ្ឍប្រទេសដើម្បីបង្កើនប្រាក់ចំណូលនាពេលខាងមុខ អាចរួមបញ្ចូលការផ្តល់ថវិកាក្នុងគម្រោងវិនិយោគភាពជាដៃគូ និងការរំលោះបំណុល។ ឧទាហរណ៍៖ ការទិញសម្ភារៈ ប្រើប្រាស់យូរឆ្នាំ ការសាងសង់ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ |

| ពាក្យគន្លឹះ | បរិយាយ |
|---|---|
| | សាធារណៈរួមមាន ផ្លូវ ស្ពាន សាលារៀន មន្ទីរពេទ្យ អគាររដ្ឋជាដើម។ |
| អង្គភាពថវិកា | សំដៅដល់អង្គភាពដែលក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិសាមី បានផ្ដល់អាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារដើម្បីបង្កើតបានជាលទ្ធផលជាក់លាក់ អាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ក្នុងវង្ងង់ឥណទានថវិកាដែលបានវិភាជជូន។ អង្គភាពថវិកាអាចជាអគ្គនាយកដ្ឋាន ឬអង្គភាពដែលមានថ្នាក់ស្មើ ឬ កម្រិតប្រហាក់ប្រហែលអគ្គនាយកដ្ឋាន ឬ នាយកដ្ឋាន ហើយមានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ ព្រមទាំងមានទំហំការងារ ចំនួនបុគ្គលិក និងទំហំថវិកាសមស្រប។ |
| អាណាប័ក | សំដៅដល់អ្នកមានសិទ្ធិអំណាចគ្រប់គ្រាន់តាមច្បាប់ក្នុងការបញ្ជាកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងវង្ងង់ឥណទានថវិការបស់ខ្លួន។ អាណាប័ករួមមានអាណាប័កដើមខ្សែ អាណាប័កផ្ទេរសិទ្ធិ និងអាណាប័កជំនួស។ |
| បន្ទុកបុគ្គលិក | សំដៅដល់ចំណាយ (ជំពូក ៦៤) លើប្រាក់បៀវត្ស អត្ថប្រយោជន៍ និង ចំណាយផ្សេងទៀតសម្រាប់មន្ត្រីរាជការ បុគ្គលិកក្របខ័ណ្ឌនិងមិនមែនក្របខ័ណ្ឌ។ |
| ក្រៅបន្ទុកបុគ្គលិក | សំដៅដល់ចំណាយដូចជា ការទិញ (សម្ភារការិយាល័យ សម្ភារសម្រាប់ការងារថែទាំនិងជួសជុល អគ្គិសនី និងទឹក បរិក្ខារថែទាំសុខភាព) ចំណាយលើសេវាកម្ម (ការជួលសេវា |

| ពាក្យគន្លឹះ | បរិយាយ |
|---|---|
| | អនាម័យ រដ្ឋបាល មធ្យោបាយដឹកជញ្ជូន សេវាថែទាំនិងជួសជុលពីសហគ្រាសឯកជន ការជួលទីតាំងសម្រាប់ការងាររដ្ឋបាល សេវាធានារ៉ាប់រង សោហ៊ុយបេសកកម្ម សេវាទូរសព្ទ ទូរសារ ឬអ៊ិនធឺណិត) បន្ទុកហិរញ្ញវត្ថុ (ការប្រាក់នៃបំណុលក្នុងនិងក្រៅប្រទេស និងបន្ទុកហិរញ្ញវត្ថុផ្សេងទៀត) ចំណាយលើការផ្តល់អត្ថប្រយោជន៍សង្គម (អត្ថ-ប្រយោជន៍សន្តិសុខសង្គម ជំនួយសង្គមដល់ប្រជាពលរដ្ឋឧបត្ថម្ភដល់អង្គភាពដែល មានលក្ខណៈសង្គមនិងវប្បធម៌និងការផ្តល់អត្ថប្រយោជន៍សង្គមផ្សេងទៀត) ការផ្តល់ឧបត្ថម្ភធន និងចំណាយក្រៅបន្ទុកបុគ្គលិកផ្សេងទៀត រួមទាំងចំណាយមិនបានគ្រោងទុកផងដែរ។ |
| ថវិកា | គឺជាផែនការហិរញ្ញវត្ថុរបស់រដ្ឋ ដែលអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ រួមមានការគ្រោងចំណូលនិងចំណាយ ការខ្ចី និងការធ្វើហិរញ្ញប្បទានបំពេញតុល្យភាពថវិកា ដើម្បីសម្រេចសមិទ្ធកម្មដែលបានគ្រោងទុក។ |

## ៣. ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺ កសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយ គុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

បេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺ ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺ អភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមនសិការស្នេហាជាតិ មោទនភាពជាតិ សីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺ ធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូប មានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្ត របស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹង វិជ្ជាជីវៈ សមត្ថភាព គុណធម៌ និងសីលធម៌ល្អ ស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែង នៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

## ៤. រចនាសម្ព័ន្ធថវិកាកម្មវិធី

ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ ២០១៥ និងបង្កើតអង្គភាពថវិកា ដើម្បីធានាភាពជាម្ចាស់នៃកម្មវិធី ដោយផ្សារភ្ជាប់រវាងធនធានទៅនឹងការទទួលខុសត្រូវចំពោះការអនុវត្តនិងសមិទ្ធកម្ម ក្នុងគោលដៅបង្កើនតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេសគឺការពង្រឹង ការបែងចែកមុខងារ ភារកិច្ច និងការទទួលខុសត្រូវឱ្យកាន់តែច្បាស់លាស់ក្នុងកម្រិតអនុវត្ត។

## ៤.១. គោលបំណងគោលនយោបាយ

ក្រសួងអប់រំ យុវជន និងកីឡា មានគោលនយោបាយអប់រំចំនួនពីរ៖ ១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា និង ២) ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ក្នុងការរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ជាពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីចូលរួមបង្កើនកំណើនការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានភាពប្រសើរជាងមុន។

## ៤.២. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកម្មវិធីចំនួន៥ ដូចខាងក្រោម៖




*រូបភាពទី 1 កម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា*

## កម្មវិធីទី១៖

- **គោលបំណងនៃកម្មវិធី៖** ពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពសម្រាប់កុមារអាយុពី ០ឆ្នាំទៅក្រោម៦ឆ្នាំ បង្កើនការចូលរៀន និងពង្រឹងការរៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ នៅកម្រិតអប់រំចំណេះទូទៅ បង្កើនអត្រាអក្ខរកម្មមនុស្សពេញវ័យ ផ្តល់ការអប់រំ ពហុភាសាដល់កុមារជនជាតិដើមភាគតិច ផ្តល់ការអប់រំពិសេសដល់កុមារពិការ និងការអប់រំបំណិនជីវិតនៅតាមសាលាមធ្យមសិក្សា។
- **ចំនួនអនុកម្មវិធី៖** ៩អនុកម្មវិធីនៅរដ្ឋបាលកណ្តាល និង១អនុកម្មវិធីនៅមន្ទីររាជធានី-ខេត្ត។

## កម្មវិធីទី២៖

- **គោលបំណងនៃកម្មវិធី៖** អភិវឌ្ឍន៍ឧត្តមសិក្សា និងការស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងតម្រូវការនៃ ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច និងឧស្សាហកម្ម។
- **ចំនួនអនុកម្មវិធី៖** ១៨អនុកម្មវិធីនៅរដ្ឋបាលកណ្តាល។

**កម្មវិធីទី៣៖**

- **គោលបំណងនៃកម្មវិធី៖** អភិវឌ្ឍន៍ធនធានមនុស្សលើវិស័យអប់រំកាយ និងកីឡាប្រកបដោយគុណភាព ប្រសិទ្ធភាព និងលើកកម្ពស់ការប្រកួតកីឡាគ្រប់ប្រភេទឱ្យមានគុណផលខ្ពស់។
- **ចំនួនអនុកម្មវិធី៖** ៦អនុកម្មវិធីនៅរដ្ឋបាលកណ្តាល និង១អនុកម្មវិធីនៅមន្ទីររាជធានី-ខេត្ត។

**កម្មវិធីទី៤៖**

- **គោលបំណងនៃកម្មវិធី៖** អនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្រ្តស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា និងឆ្លើយតបតាមតម្រូវការចាំបាច់របស់យុវជន។
- **ចំនួនអនុកម្មវិធី៖** ៣អនុកម្មវិធីនៅរដ្ឋបាលកណ្តាល និង១អនុកម្មវិធីនៅមន្ទីររាជធានី-ខេត្ត។

**កម្មវិធីទី៥៖**

- **គោលបំណងនៃកម្មវិធី៖** ពង្រឹងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលការងារវិមជ្ឈការនិងវិសហមជ្ឈការ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។
- **ចំនួនអនុកម្មវិធី៖** ១៧ អនុកម្មវិធីនៅរដ្ឋបាលកណ្តាល និង ១ អនុកម្មវិធីនៅមន្ទីររាជធានី-ខេត្ត។

## ៤.៣. ការរៀបចំអង្គភាពថវិកា

ដើម្បីឱ្យអង្គភាពនីមួយៗមានទាំងគោលនយោបាយ និងថវិកា សម្រាប់ការអនុវត្តគោលនយោបាយ ក្នុងគោលដៅពង្រឹងភាពជាម្ចាស់ការទទួលខុសត្រូវ គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តថវិកា ក្រសួងបានរៀបចំប្រកាសអន្តរក្រសួងលេខ ៩១១ សហវ.ប្រក.អថ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ បានប្រកាសទទួលស្គាល់និងដាក់ឱ្យអនុវត្តអង្គភាពថវិកាចំនួន៥៧អង្គភាព ក្នុងនោះរដ្ឋបាល

កណ្តាលមានចំនួន៣២ និងមន្ទីររាជធានី-ខេត្តមានចំនួន ២៥ នៅក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

រដ្ឋបាលកណ្តាល ចំនួន ៣២ អង្គភាព

- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញចំនួន១៩
- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១៣

មន្ទីររាជធានី ខេត្ត ចំនួន ២៥ អង្គភាព

- អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ២៥

*រូបភាពទី 2 អង្គភាពថវិកាឆ្នាំ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា*

# ៥. ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ ២០២៤

## ៥.១. ស្ថានភាពចំណូល




*រូបភាពទី 3 ចំណូលរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៤*

រូបភាពខាងលើបានបង្ហាញឱ្យឃើញថា ៖

- **ភាគលាភរបស់សហគ្រាសសាធារណៈ៖** ថវិកាសរុបចំនួន ១៥០លានរៀល មានការថយចុះចំនួន ៤៦៩.៤លានរៀល ស្មើនឹង ៧៥.៨% ធៀបច្បាប់ថវិកាឆ្នាំ២០២៣។
- **ផលពីការបង្កើតសហគ្រាស៖** ថវិកាសរុបចំនួន ៧៥០លានរៀល មានការកើនឡើងចំនួន ១៥០លានរៀល ស្មើនឹង ១១៥.០% ធៀបច្បាប់ថវិកាឆ្នាំ២០២៣។
- **ផលពីការបង់សិទ្ធិប្រឡង៖** ថវិកាសរុបចំនួន ៤៥.៥លានរៀលស្មើនឹងច្បាប់ថវិកាឆ្នាំ២០២៣។
- **ការជួលដីទំនេរ៖** ថវិកាសរុបចំនួន ១៣៩១.៦លានរៀលកើនឡើងចំនួន ១៦.៨លានរៀល ដែលគិតជាភាគរយ ស្មើនឹង ១០១.០% ធៀបច្បាប់ថវិកាឆ្នាំ២០២៣។

## ៥.២. ស្ថានភាពចំណាយរបស់ក្រសួងក្នុងឆ្នាំ២០២៤

រាជរដ្ឋាភិបាលក្នុងអាណត្តិទី៧ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាក្នុងការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិនិងយោធិន និងមន្ត្រីជាប់កិច្ចសន្យាមានដូចខាងក្រោមៈ

- គ្រោងដំឡើងបៀវត្សមូលដ្ឋាន៖ ចំនួន ៥% គិតចាប់ពីខែមករា ដល់ខែធ្នូ ដោយត្រូវដំឡើងតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋានពី ២ ៥០០ រៀល ក្នុង ១ ឯកតាសន្ទស្សន៍ នៅឆ្នាំ២០២៣ ទៅ ២ ៦៣០ រៀល ក្នុង ១ ឯកតាសន្ទស្សន៍ នៅឆ្នាំ២០២៤។
- គ្រោងដំឡើងប្រាក់បំណាច់មុខងារ៖
    - សម្រាប់ផ្តល់ជូនមន្ត្រីរាជការស៊ីវិល៖
        - ❖ បន្ថែមជូន ២២ ៥០០ រៀល សម្រាប់មន្ត្រីរាជការស៊ីវិលដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ១ ១៣០ ០០០ រៀលចុះក្រោម
        - ❖ បន្ថែមជូន ២០ ០០០ រៀល សម្រាប់មន្ត្រីរាជការ ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ១ ១៣០ ១០០ រៀល ឡើងទៅ

- សម្រាប់ផ្តល់ជូនមន្ត្រីនគរបាលជាតិនិងយោធិន៖
  - ❖ បន្ថែមជូន ២៥ ០០០ រៀល សម្រាប់មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារ ក្នុងកម្រិតចាប់ពី ៩៦០ ០០០ រៀល ចុះក្រោម
  - ❖ បន្ថែមជូន ២០ ០០០ រៀល សម្រាប់មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី ៩៦០ ១០០ រៀល ឡើងទៅ ដោយគិតចាប់ពីខែមេសា ដល់ខែ ធ្នូ។

- គ្រោងប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ និងក្នុងឱកាស បុណ្យភ្ជុំបិណ្ឌចំនួន ៥ ម៉ឺនរៀល ក្នុងម្នាក់ ជូនដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងនិវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ដែលជាអតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន និង
- គ្រោងចំនួនមន្ត្រីជាប់កិច្ចសន្យាមិនឱ្យលើសពីចំនួន ដែលក្រសួងមុខងារសាធារណៈផ្តល់ជូន ក្នុងឆ្នាំ ២០២៣ ដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំពោះមន្ត្រីជាប់កិច្ចសន្យា ត្រូវគ្រោងដំឡើងពី ៧១០ ០០០ រៀល ទៅដល់ ៧៧០ ០០០ រៀល ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ។

### ៥.២.១. ស្ថានភាពចំណាយរបស់ក្រសួង




*រូបភាពទី 4 ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៣* - ២០២៤* (ចំណាយចរន្ត និងចំណាយមូលធន)*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*
** ឆ្នាំ២០២៣ គិតបញ្ចូលផ្ទេរពាមុខងារនៅខេត្តបាត់ដំបង*
** ឆ្នាំ២០២៤ គិតបញ្ចូលផ្ទេរពាមុខងារទូទាំងប្រទេស*

បើគិតបញ្ចូលថវិកាផ្ទេរពាមុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅឆ្នាំ ២០២៤ សរុបចំនួន ៣ ៨១៦ ០១១.០លានរៀល កើនឡើង ១១១.៥% ធៀបឆ្នាំ២០២៣ ក្នុងនោះចំណាយចរន្តចំនួន ៣ ៧៣៦ ០១១.០លានរៀល និងចំណាយមូលធន ចំនួន ៨០ ០០០.០ លានរៀល។




*រូបភាពទី 5 ថវិកាចំណាយចរន្តឆ្នាំ២០២៣*-២០២៤* ធៀបនឹងចំណាយចរន្តថ្នាក់ជាតិ*
*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*
** ឆ្នាំ២០២៣ គិតបញ្ចូលផ្ទេរពាមុខងារនៅខេត្តបាត់ដំបង*
** ឆ្នាំ២០២៤ គិតបញ្ចូលផ្ទេរពាមុខងារទូទាំងប្រទេស*

សម្រាប់ឆ្នាំ ២០២៤ ថវិកាចំណាយចរន្ត ដោយគិតបញ្ចូលទាំងបន្ទុកបុគ្គលិក និងក្រៅបន្ទុកបុគ្គលិក របស់អង្គភាពរដ្ឋបាលកណ្តាល មន្ទីររាជធានីខេត្ត និងការផ្ទេរ

៣មុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានពិនិត្យឃើញថា ភាគរយប្រៀបធៀបជាមួយចំណាយចរន្តថ្នាក់ជាតិគឺធ្លាក់ចុះមិនធ្លាប់មាន ដោយបានធ្លាក់ចុះពី ១៦.៩% មក ១៥.៧% បើទោះបីជាទំហំឥណទានចំណាយចរន្តរបស់ក្រសួងបានកើនឡើងក្តី ប៉ុន្តែដោយសារទំហំនៃ ផ.ស.ស បានកើនឡើងពី ១៣១ ២៦៤ ប៊ីលានរៀល មក ១៤២ ៩៥៧ ប៊ីលានរៀល។




*រូបភាពទី 6 ចំណាយបន្ទុកបុគ្គលិក និងក្រៅបន្ទុកបុគ្គលិក របស់ក្រសួង ឆ្នាំ២០២៤*
*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

រូបភាពខាងលើបានបង្ហាញថា នៅឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវចំណាយថវិកាលើបន្ទុកបុគ្គលិករហូតដល់ ៨១.៤% នៃឥណទានសរុបរបស់ក្រសួង និងចំណាយក្រៅបន្ទុកបុគ្គលិក ចំនួន ១៨.៦% នៃឥណទានសរុបរបស់ក្រសួង។




*រូបភាពទី 7 ថវិការបស់រដ្ឋបាលកណ្ដាល មន្ទីររាជធានី-ខេត្ត និងផ្ទេរ៣មុខងារ ឆ្នាំ ២០២៣-២០២៤*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

នៅឆ្នាំ២០២៤ ថវិការបស់អង្គភាពរដ្ឋបាលកណ្ដាលមានចំនួន ៤២០ ៤២៥.៤លានរៀល កើនឡើងចំនួន ៤២ ៩៤៦.៨លានរៀល ស្មើនឹង១១១.៤% ធៀបច្បាប់ថវិកាឆ្នាំ២០២៣របស់រដ្ឋបាលកណ្ដាល ដោយឡែកសម្រាប់មន្ទីររាជធានីខេត្តមានចំនួន ១ ៥៦៥ ៣០៧.៩លានរៀល នៅឆ្នាំ២០២៤ ថយចុះចំនួន (១ ៤១៩ ០៣៩.១)លានរៀល ស្មើនឹង ៥២.៥% ធៀបច្បាប់ថវិកាឆ្នាំ២០២៣របស់មន្ទីររាជធានី-ខេត្ត។ សម្រាប់ថវិកាផ្ទេរ៣មុខងារគឺមានចំនួន ១ ៧៥០ ២៧៧.៧ លានរៀល កើនឡើងចំនួន ១ ៥៩៩ ៧៨៤.៣លានរៀល ស្មើនឹង ១០៦.៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៣ ដែលបានផ្ទេរ។ មូលហេតុនៃបម្រែបម្រួលយ៉ាងខ្លាំងរវាងថវិកាមន្ទីររាជធានី-ខេត្ត និងថវិកាផ្ទេរ៣មុខងារគឺដោយសារនៅឆ្នាំ២០២៤ ក្រសួងបានផ្ទេរថវិកា៣មុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងក្របខណ្ឌ ទូទាំងប្រទេស រីឯឆ្នាំ២០២១ គឺបានផ្ទេរសាកល្បងនៅខេត្តបាត់ដំបងចំនួន ១៤ក្រុង ស្រុក។

*.តារាងឧបសម្ព័ន្ធនៃថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា៖

ឯកតា លានរៀល

| កម្មវិធី- អនុកម្មវិធី | ច្បាប់ ២០២៤ |
|---|---|
| សរុបថវិការួម | 3,816,011.0 |
| ថវិកាផ្ទេរបើអនុវិស័យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 1,750,277.7 |
| សរុបរួមរដ្ឋបាលកណ្តាល និងមន្ទីរ | 2,065,733.3 |
| សរុបចំណាយចរន្ត | 1,985,733.3 |
| កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ | 232,358.7 |
| អនុកម្មវិធីទី១៖ ការពង្រីកការអប់រំកុមារតូច | 15,385.0 |
| អនុកម្មវិធីទី២៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា | 6,408.2 |
| អនុកម្មវិធីទី៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា | 6,525.1 |
| អនុកម្មវិធីទី៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ | 1,851.2 |
| អនុកម្មវិធីទី៥៖ ការពង្រឹង និងការពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា | 1,273.7 |
| អនុកម្មវិធីទី៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស | 2,902.9 |
| អនុកម្មវិធីទី៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន | 7,980.2 |
| អនុកម្មវិធីទី៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ | 27,308.1 |
| អនុកម្មវិធីទី៩៖ ពង្រីកការអប់រំបរិយាបន្នគ្រប់ភូមិសិក្សា | 593.0 |
| អនុកម្មវិធីទី១០៖ សៅគាំទ្រការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងមិនផ្លូវការរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 162,131.3 |
| កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ | 47,264.9 |

| កម្មវិធី- អនុកម្មវិធី | ច្បាប់ ២០២៤ |
|---|---|
| អនុកម្មវិធីទី១៖ ការលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា | 2,570.3 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា | 1,383.9 |
| អនុកម្មវិធីទី៣៖ ការពង្រឹងគុណភាព និងភាពឆ្លើយតបនៃការបណ្តុះបណ្តាលកម្រិតឧត្តម និងក្រោយឧត្តមប្រកបដោយប្រសិទ្ធភាព | 2,713.0 |
| អនុកម្មវិធីទី៤៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំបណ្តុះបណ្តាល និងស្រាវជ្រាវ | 1,526.2 |
| អនុកម្មវិធីទី៥៖ ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនិងស្រាវជ្រាវ | 2,195.7 |
| អនុកម្មវិធីទី៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ | 5,421.1 |
| អនុកម្មវិធីទី៧៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូ និងស្រាវជ្រាវ | 9,623.2 |
| អនុកម្មវិធីទី៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលនិងការស្រាវជ្រាវ | 3,173.7 |
| អនុកម្មវិធីទី៩៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំនិងស្រាវជ្រាវ | 1,541.2 |
| អនុកម្មវិធីទី១០៖ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំនិងការស្រាវជ្រាវ | 2,751.9 |
| អនុកម្មវិធីទី១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា | 615.8 |
| អនុកម្មវិធីទី១៤៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំការស្រាវជ្រាវនិងសេវាសហគមន៍លើផ្នែកបច្ចេកវិទ្យា | 1,801.2 |
| អនុកម្មវិធីទី១៥៖ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ | 1,349.0 |
| អនុកម្មវិធីទី១៦៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវលើផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ | 1,407.4 |
| អនុកម្មវិធីទី១៧៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការ | 4,286.9 |

| កម្មវិធី- អនុកម្មវិធី | ច្បាប់ ២០២៤ |
|---|---|
| អប់រំគ្រូបង្រៀនឆ្លើយស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ | |
| អនុកម្មវិធីទី១៨៖ ពង្រឹងគុណភាពបណ្តុះបណ្តាល វិក្រឹតការគ្រូ និងការស្រាវជ្រាវ ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ | 4,904.4 |
| **កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា** | **61,117.4** |
| អនុកម្មវិធីទី១៖ ការអភិវឌ្ឍកីឡាមហាជន | 6,009.1 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍអប់រំកាយ និងកីឡាសិស្ស និស្សិត | 2,345.7 |
| អនុកម្មវិធីទី៣៖ ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយ និងកីឡា | 3,011.0 |
| អនុកម្មវិធីទី៤៖ ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | 21,599.2 |
| អនុកម្មវិធីទី៥៖ ការអភិវឌ្ឍការប្រកួត និងគ្រប់គ្រងព្រឹត្តិការណ៍កីឡាគ្រប់កម្រិត | 10,940.4 |
| អនុកម្មវិធីទី៦៖ ការអភិវឌ្ឍផ្នែកព័ត៌មាន និងស្ថិតិកីឡាគ្រប់ប្រភេទ | 618.8 |
| អនុកម្មវិធីទី៧៖ សេវាគាំទ្រការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា របស់មន្ទីរជំនាញរាជធានី-ខេត្ត | 16,593.2 |
| **កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន** | **14,788.4** |
| អនុកម្មវិធីទី១៖ ការអភិវឌ្ឍសកម្មភាពយុវជន | 5,572.3 |
| អនុកម្មវិធីទី២៖ ការអភិវឌ្ឍមជ្ឈមណ្ឌលយុវជន | 2,628.9 |
| អនុកម្មវិធីទី៣៖ ការអភិវឌ្ឍកាយរឹទ្ធិកម្ម | 1,060.6 |
| អនុកម្មវិធីទី៤៖ សេវាគាំទ្រការអភិវឌ្ឍយុវជនរបស់មន្ទីរជំនាញរាជធានី-ខេត្ត | 5,526.6 |
| **កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ** | **1,630,203.9** |
| អនុកម្មវិធីទី១៖ ការអភិវឌ្ឍ និងពង្រឹងប្រព័ន្ធផែនការអប់រំ | 1,665.4 |
| អនុកម្មវិធីទី២៖ ការគ្រប់គ្រង និងពង្រឹងប្រសិទ្ធភាពធនធានមនុស្ស | 128,998.2 |

| កម្មវិធី- អនុកម្មវិធី | ច្បាប់ ២០២៤ |
|---|---|
| អនុកម្មវិធីទី៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ ការអភិវឌ្ឍសមត្ថភាព ការគាំទ្រការលើកកម្ពស់គុណភាពអប់រំ និងមូលដ្ឋានសម្ភារ | 94,521.4 |
| អនុកម្មវិធីទី៤៖ ការពង្រឹងការងារសវនកម្មផ្ទៃក្នុង | 583.2 |
| អនុកម្មវិធីទី៥៖ ការពិនិត្យតាមដាន វាយតម្លៃ និងអធិការកិច្ច ប្រព័ន្ធធានាគុណភាពអប់រំ | 2,862.0 |
| អនុកម្មវិធីទី៦៖ អធិការកិច្ចរដ្ឋបាល និងហិរញ្ញវត្ថុ | 386.8 |
| អនុកម្មវិធីទី៧៖ លើកកម្ពស់ការផ្សព្វផ្សាយព័ត៌មានអប់រំ និងកិច្ចសហប្រតិបត្តិការ អាស៊ាន និងស៊ីមេអូ | 1,040.2 |
| អនុកម្មវិធីទី៨៖ ការពង្រឹងការងារនីតិកម្ម | 759.8 |
| អនុកម្មវិធីទី៩៖ ការពង្រឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ | 6,176.6 |
| អនុកម្មវិធីទី១០៖ ការពង្រឹងការគ្រប់គ្រង ការផ្គត់ផ្គង់សម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | 2,331.3 |
| អនុកម្មវិធីទី១១៖ ការអភិវឌ្ឍ និងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រង និងការធានាភាពស័ក្តិសិទ្ធិនៃសេវារដ្ឋបាលអប់រំ | 2,028.9 |
| អនុកម្មវិធីទី១២៖ ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ លើវិស័យអប់រំ | 4,332.3 |
| អនុកម្មវិធីទី១៣៖ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | 883.5 |
| អនុកម្មវិធីទី១៤៖ អភិវឌ្ឍន៍គោលនយោបាយអប់រំ និងការស្រាវជ្រាវ | 1,009.3 |
| អនុកម្មវិធីទី១៥៖ អភិវឌ្ឍន៍ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ | 731.3 |
| អនុកម្មវិធីទី១៦៖ ការអភិវឌ្ឍនិងពង្រឹងប្រព័ន្ធព័ត៌មានវិទ្យា | 836.9 |
| អនុកម្មវិធីទី១៨៖ សេវាគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ របស់មន្ទីរជំនាញរាជធានី-ខេត្ត | 1,381,056.8 |
| **សរុបចំណាយមូលធន** | **80,000.0** |

## ៥.២.២. ថវិការបស់អង្គភាពរដ្ឋបាលកណ្តាល




*រូបភាពទី ៨ ថវិការបស់រដ្ឋបាលកណ្តាលឆ្នាំ២០២៣-២០២៤*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

រូបភាពខាងលើបានបង្ហាញថា នៅឆ្នាំ២០២៤ អង្គភាពរដ្ឋបាលកណ្តាលចំណាយថវិកាលើបន្ទុកបុគ្គលិកចំនួន ១២៩ ៦៣៩.៨លានរៀល កើនឡើងចំនួន ៧ ៦២៥.៨លានរៀល ស្មើនឹង ១០៦.២% ធៀបច្បាប់ថវិកាបន្ទុកបុគ្គលិកឆ្នាំ២០២៣ ឬស្មើនឹង ៣០.៨% នៃឥណទានសរុបរបស់រដ្ឋបាលកណ្តាល និងចំណាយក្រៅបន្ទុកបុគ្គលិកចំនួន ២៩០ ៧៨៥.៦លានរៀល កើនឡើងចំនួន៣៥ ៣២១.១លានរៀល ស្មើនឹង ១១៣.៨% ធៀបច្បាប់ថវិកាក្រៅបន្ទុកបុគ្គលិកឆ្នាំ២០២៣ ឬស្មើនឹង ៦៩.២% នៃឥណទានសរុបរបស់អង្គភាពរដ្ឋបាលកណ្តាល។




*រូបភាពទី ១ ថវិកាតាមកម្មវិធីរបស់រដ្ឋបាលកណ្ដាល ឆ្នាំ២០២៤*
*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

រូបភាពខាងលើបានបង្ហាញថា នៅកម្មវិធីទី៥ មានថវិកាច្រើនជាងគេ គឺចំនួន ២៤៩ ១៤៧.១លានរៀល មូលហេតុដែលនាំឱ្យកម្មវិធីនេះមានឥណទានច្រើនជាងគេ គឺដោយសារចំណាយលើបន្ទុកបុគ្គលិករបស់មន្ត្រីរាជការ និងមន្ត្រីមិនមែនក្របខ័ណ្ឌនៅរដ្ឋបាលកណ្ដាលត្រូវបានគ្រោងកម្មវិធីនេះ។

## ៥.២.៣. ថវិការបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត




*រូបភាពទី 10 ថវិការបស់មន្ទីររាជធានី-ខេត្ត ឆ្នាំ២០២៣-២០២៤*
*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

រូបភាពខាងលើបានបង្ហាញថា នៅឆ្នាំ២០២៤ មន្ទីររាជធានី-ខេត្ត ចំណាយថវិកាលើបន្ទុកបុគ្គលិកចំនួន ១ ២៦៨ ៤៧៤.១លានរៀល ថយចុះចំនួន (១ ៣៤៩ ៨៨៥.៣)លានរៀល ស្មើនឹង ៤៨.៤% ធៀបច្បាប់ថវិកាបន្ទុកបុគ្គលិកឆ្នាំ២០២៣ ឬស្មើនឹង ៨១.0% នៃឥណទានសរុបរបស់មន្ទីររាជធានី-ខេត្តនិងចំណាយក្រៅបន្ទុកបុគ្គលិកចំនួន ២៩៦ ៨៣៣.៨លានរៀល ថយចុះចំនួន (៦៩ ១៥៣.៨) លានរៀលស្មើនឹង ៨១.១%ធៀបច្បាប់ថវិកាក្រៅបន្ទុកបុគ្គលិកឆ្នាំ២០២៣ ឬស្មើនឹង ១៨.៩% នៃឥណទានសរុបរបស់មន្ទីររាជធានី-ខេត្ត។

## ៥.២.៤. ការផ្ទេរថវិកា ៣មុខងារឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ




*រូបភាពទី 11 ទំហំថវិកាផ្ទេរ៣មុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ឆ្នាំ២០២៤*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

រូបភាពខាងលើបានបង្ហាញថា នៅឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡា បានផ្ទេរថវិកា៣មុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នូវមុខងារគ្រប់គ្រងអប់រំកុមារតូច មុខងារគ្រប់គ្រងបឋមសិក្សា និងមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ដែលមានឥណទានថវិកាសរុបទាំងបន្ទុកបុគ្គលិក និង ក្រៅបន្ទុកបុគ្គលិកចំនួន ១ ៧៥០ ២៧៧.៧លានរៀល ស្មើនឹង ៤៦.៨% នៃថវិកាសរុបរបស់ក្រសួង រីឯថវិកានៅមន្ទីររាជធានី-ខេត្តទាំង២៥ ចំនួន ៤១.៩% និងអង្គភាពរដ្ឋបាលកណ្ដាលចំនួន ១១.៣% នៃថវិកាសរុបរបស់ក្រសួង។

សម្រាប់ថវិកាទាំង៣មុខងារដែលបានផ្ទេរក្នុងនោះមាន៖

- មុខងារគ្រប់គ្រងអប់រំកុមារតូច ចំនួន ៤ ៤៨៨.១លានរៀល
- មុខងារគ្រប់គ្រងបឋមសិក្សា ចំនួន ៩៧ ៤៦០.៣លានរៀល
- មុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ចំនួន ៣ ៩៨៧.៥លានរៀល

• ប្រាប់បៀវត្សមន្ត្រីទាំង៣មុខងារខាងលើ ចំនួន ១ ៦៤៤ ៣៤១.៨លានរៀល




*រូបភាពទី 12 ការផ្ទេរ៣មុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមមន្ទីររាជធានី-ខេត្ត*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

## ៥.៣. មុខសញ្ញាចំណាយសំខាន់ៗរបស់ក្រសួង

នៅឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តោតការចំណាយថវិកាលើមុខសញ្ញាចំណាយសំខាន់ៗ និងអាទិភាព ដូចខាងក្រោម៖

ឯកតា៖ លានរៀល

| ល.រ | បរិយាយ | ឥណទាន |
|---|---|---|
| 1 | ប្រាក់បៀវត្សមន្ត្រីរាជការសម្រាប់រដ្ឋបាលកណ្តាល និងមន្ទីររាជធានី-ខេត្ត | 1,398,113.9 |
| 2 | ប្រាក់បៀវត្សមន្ត្រីរាជការ ដែលបានផ្ទេរពាមុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 1,644,341.8 |
| 3 | ថវិកាសម្រាប់ចំណាយក្នុងកិច្ចដំណើរការមត្តេយ្យសិក្សាសហគមន៍ និងប្រាក់បៀវត្សគ្រូមត្តេយ្យសិក្សាសហគមន៍ | 14,006.1 |
| 4 | ថវិកាសម្រាប់ចំណាយលើមូលនិធិដំណើរការសាលារៀនសាធារណៈ | 157,154.6 |
| 5 | ប្រាក់ឧបត្ថម្ភអាហារូបករណ៍ផ្តល់ជូនសិស្សក្រីក្រនិងជួបការលំបាកនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា | 64,292.9 |
| 6 | ប្រាក់ឧបត្ថម្ភអាហារូបករណ៍របស់គរុសិស្ស និងគរុនិស្សិតនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ | 26,579.9 |
| 7 | ថវិកាគាំទ្រកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ចំនួន១០ខេត្ត សាលាគោលដៅចំនួន៥៥៣ | 22,712.1 |
| 8 | ថវិកាសម្រាប់ចំណាយក្នុងការផ្គត់ផ្គង់សៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាសម្រាប់ផ្តល់ជូនគ្រូនិងសិស្ស | 27,668.8 |
| 9 | ថវិកាគាំទ្រសាលាជំនាន់ថ្មីនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា | 9, 069.0 |
| 10 | ថវិកាសម្រាប់ចំណាយក្នុងកម្មវិធីអំណានដំបូងថ្នាក់ទី១នៅខេត្តកណ្តាលនិងត្បូងឃ្មុំ | 4,007.5 |

| ល.រ | បរិយាយ | ឥណទាន |
|---|---|---|
| 11 | ថវិកាគាំទ្រកិច្ចដំណើរការសម្រាប់សកម្មភាពបណ្ដាញសាកលវិទ្យាល័យសាយប័រកម្ពុជា (Cyber University) | 2,163.0 |
| 12 | ថវិកាគាំទ្រការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា | 44,524.2 |
| 13 | ថវិកាគាំទ្រការអភិវឌ្ឍយុវជន | 9,261.8 |
| 14 | ថវិកាសម្រាប់ចំណាយក្នុងការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្សថ្នាក់ទី៥(SEA-PLM) | 753.9 |
| 15 | ថវិកាសម្រាប់ចំណាយក្នុងកិច្ចដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | 36,424.7 |
| 16 | ថវិកាសម្រាប់ចំណាយក្នុងការប្រឡងបញ្ចប់ឆ្នាំទី១ ឆ្នាំទី២ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ | 1,283.1 |
| 17 | ថវិកាសម្រាប់ចំណាយក្នុងការជ្រើសរើស ប្រឡងជ្រើសរើស និងបញ្ចប់ការសិក្សារបស់និស្សិតអាហារូបករណ៍នៅតាមគ្រឹះស្ថានឧត្តមសិក្សា | 2,954.9 |
| 18 | ថវិកាសម្រាប់ចំណាយក្នុងកិច្ចដំណើរការគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ (សាលាគរុ. និងវិក្រឹត្យការនិងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ) | 4,184.7 |
| 19 | ថវិកាគាំទ្របន្ថែមជូនការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | 6,240.0 |
| 20 | ថវិកាសម្រាប់ចំណាយក្នុងកិច្ចដំណើរការវិទ្យាល័យអប់រំពិសេសចំនួន៦ | 2,636.0 |
| 21 | ថវិកាសម្រាប់ចំណាយក្នុងការសាងសង់បង្គន់អនាម័យ និងប្រព័ន្ធទឹកស្អាតនៅតាមសាលារៀនសាធារណៈចំនួន ៣៦០ | 4,968.0 |
| 22 | ថវិកាសម្រាប់ចំណាយក្នុងការជួសជុលអគារសិក្សានិងអគាររដ្ឋបាលតាមមន្ទីរអប់រំ យុវជន និងរាជធានី ខេត្ត | 36,212.3 |

| ល.រ | បរិយាយ | ឥណទាន |
|---|---|---|
| 23 | ថវិកាសម្រាប់ចំណាយក្នុងការជួសជុលនិងថែទាំលើអគាររដ្ឋបាល គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ និងអគារសិក្សាសាធារណៈថ្នាក់កណ្ដាល | 9,192.6 |
| 24 | ថវិកាសម្រាប់ចំណាយក្នុងការផ្គត់ផ្គង់តុនិងកៅអី ផ្តល់ជូនគ្រូបង្រៀននិងសិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សាសាធារណៈទូទាំងប្រទេសនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ | 10,000.0 |

## ៥.៣.១. ថវិកាបន្ទុកបុគ្គលិក




*រូបភាពទី 13 ថវិកាបន្ទុកបុគ្គលិក*

រូបភាពខាងលើបានបង្ហាញថា នៅឆ្នាំ២០២៤ ក្រសួងអប់រំ យុវជន និងកីឡា ចំណាយថវិកាលើបន្ទុកបុគ្គលិកកើនឡើងពីចំនួន ២ ៨៨២ ៣៨៧.០លានរៀល មកចំនួន ៣ ០៤២ ៤៥៥.៧លានរៀល ស្មើនឹង ៨១.៤% នៃឥណទានសរុបរបស់ក្រសួង។

## ៥.៣.២. ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ




| | 2023 | 2024 |
|---|---|---|
| ថវិកា SOF | 148,332.4 | 157,154.6 |
| %ធៀបក្រសួង | 4.4% | 4.2% |
| %ធៀបក្រៅបន្ទុក. | 23.9% | 22.7% |
| អត្រាកំណើន | 105.0% | 105.9% |

*រូបភាពទី 14 ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈឆ្នាំ២០២៣-២០២៤*
*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

នៅក្នុងឆ្នាំ ២០២៤ ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈមានចំនួន ១៥៧ ១៥៤.៦ លានរៀលស្មើនឹង ៤.២% បើប្រៀបធៀបជាមួយនឹងថវិកាសរុបរបស់ក្រសួងកើន ឬស្មើនឹង ២២.៧% ធៀបជាមួយថវិកាក្រៅបន្ទុកបុគ្គលិក ព្រមទាំងមានអត្រាកំណើន ១០៥.៩% ធៀបនឹងថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ ឆ្នាំ ២០២៣។

គួរបញ្ជាក់ផងដែរថា នៅឆ្នាំ២០២៤ សាលារៀនទូទាំងប្រទេសសរុបទាំងអគារធនធានដែលនៅក្នុងវិទ្យាល័យមានចំនួន ៩ ៥៦៩សាលា ហើយសាលារៀនសាធារណៈត្រូវអនុវត្តចំណាយរបស់ខ្លួន ដោយអនុលោមទៅតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ ដែលមានសកម្មភាព ២ ធំៗដូចជា៖

- **គាំទ្រកិច្ចដំណើរការ ៖** ចំណាយទៅលើ ការគាំទ្រការងាររដ្ឋបាល ការងារប្រឡង សម្ភារៈបរិក្ខារ និងសង្ហារិម ចំណាយលើសេវាកម្មផ្សេងៗ ការថែទាំ

ការសាងសង់ និងជួសជុល។

- **កែលម្អគុណភាពអប់រំ ៖** ចំណាយទៅលើ ការចូលរៀនដោយសមធម៌និងបង្ការសិស្សបោះបង់ សម្ភារៈរៀននិងបង្រៀន ការកែលម្អបរិស្ថាននិងទីធ្លា កម្សាន្ត អប់រំបំណិនជីវិត កីឡា ការងារយុវជន និងកុមារ។

## ៥.៣.៣. ថវិកាអាហារូបករណ៍សិស្សក្រីក្រ




*រូបភាពទី 15 ថវិកាអាហារូបករណ៍សិស្សក្រីក្រ ឆ្នាំ២០២៣-២០២៤*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា៖*

ការផ្តល់ថវិកាអាហារូបករណ៍ជូនសិស្សក្រីក្រជួបការលំបាក ដែលកំពុងសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈមានចំនួន ៦៤ ២៩២.៩លានរៀល សិស្សសរុបចំនួន ២៦២ ៣៣០នាក់។

យោងតាមលិខិតលេខ ៣៤ អនក្រ.បក ចុះនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ការផ្តល់អាហារូបករណ៍ ដល់សិស្សក្រីក្រនៅបឋមសិក្សានិងមធ្យមសិក្សាចំណេះទូទៅនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវផ្តល់ជូនក្នុងមួយឆ្នាំសិក្សាដល់សិស្សក្រីក្រម្នាក់ៗ ទៅតាមកម្រិតដូចខាងក្រោម៖

- បឋមសិក្សា ៖ ទទួលបានថវិកាចំនួន ២៤០ ០០០រៀល/ម្នាក់/ឆ្នាំសិក្សា
- មធ្យមសិក្សាបឋមភូមិ ៖ ទទួលបានថវិកាចំនួន ២៤០ ០០០រៀល/ម្នាក់/ឆ្នាំសិក្សា
- មធ្យមសិក្សាទុតិយភូមិ៖ ទទួលបានថវិកាចំនួន ៣៦០ ០០០រៀល/ម្នាក់/ឆ្នាំសិក្សា

## ៥.៣.៤. កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍

កម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានអនុវត្តនៅកម្ពុជាតាំងពីឆ្នាំ១៩៩៩ ដោយចាប់ផ្តើមពី ៦៤ សាលា មានសិស្ស ៣៧ ៥០០នាក់ ដោយប្រើប្រាស់ស្បៀងដែលផ្តល់ពីកម្មវិធីស្បៀងអាហារពិភពលោក ហើយកម្មវិធីនេះបានពង្រីកវិសាលភាពជាបន្តបន្ទាប់រហូតមកដល់ឆ្នាំ២០១៤។ កម្មវិធីផ្តល់អាហារតាមសាលារៀនក៏បានចាប់ផ្តើមអនុវត្តសាកល្បងកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ជាកម្មវិធីថ្មីមួយនៅកម្ពុជាដែលបានប្រើប្រាស់ផលិតផលកសិករក្នុងមូលដ្ឋានស្ទើរតែទាំងស្រុង លើកលែងតែអំបិលនិងប្រេងឆា។ គោលបំណងនៃកម្មវិធីនេះគឺ ១) បង្កើនអាហារូបត្ថម្ភចម្រុះដល់កុមារ ជួយឱ្យមានសុខភាពល្អ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមចំណែក លើកស្ទួយផ្នែកសុខភាព សតិបញ្ញា ស្មារតី និងអារម្មណ៍កុមារឱ្យទទួលបានការរៀនសូត្រកាន់តែប្រសើរ។ ២) បង្កើនអត្រាចូលរៀននិងមករៀនបានទៀងទាត់ ទាន់ពេលវេលា បង្កើនអត្រាឡើងថ្នាក់ អត្រាបញ្ចប់កូមិសិក្សានៅកម្រិតបឋមសិក្សា និងកាត់បន្ថយអត្រាបោះបង់ការសិក្សា និង ៣) បង្កើនចំណូលជូនប្រជាពលរដ្ឋក្នុងសហគមន៍គោលដៅ តាមរយៈការជំរុញឱ្យមានផលិតកម្មស្បៀងចម្រុះ ដើម្បីផ្គត់ផ្គង់ដល់សាលារៀន និងកាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតាសិស្សបានមួយកម្រិត។

ឆ្នាំសិក្សា២០១៩-២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចទទួលការផ្ទេរសាលារៀនគោលដៅពីកម្មវិធីស្បៀងអាហារពិភពលោកជាបណ្តើរៗ មកអនុវត្តជាកម្មវិធីជាតិ ក្រោមរូបភាពកម្មវិធីអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ដែលមានចំនួន៦ ខេត្ត ស្មើនឹង២០៥ សាលារៀន និងមានចំនួនសិស្សទទួលទានអាហារចំនួន ៤០ ៩០៥នាក់ ចំណាយថវិកាចំនួន ៧ ០៧២.៤លានរៀល ជាឆ្នាំដំបូង។




| | 1 | 2 |
|---|---|---|
| ឆ្នាំ | 2023 | 2024 |
| ចំនួនខេត្ត | 10 ខេត្ត | 10 ខេត្ត |
| ចំនួនសាលា | 427 សាលា | 553 សាលា |
| ចំនួនសិស្ស | 110,645 នាក់ | 148,565 នាក់ |
| ទឹកប្រាក់ | 17,079.6 លានរៀល | 22,712.1 លានរៀល |



*រូបភាពទី 16 ថវិកាកម្មវិធីស្បៀងអាហារតាមសាលារៀនឆ្នាំ២០២៣-២០២៤*
*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

នៅឆ្នាំ២០២៤ ក្រសួងចំណាយលើកម្មវិធីអាហារូបត្ថម្ភតាមសាលារៀន ដោយបានពង្រីកគោលដៅចំនួន ១០ ខេត្ត ស្មើនឹង៥៥៣សាលារៀន ដែលមានចំនួនសិស្សទទួលទានអាហារចំនួន ១៤៨ ៥៦៥នាក់ ចំណាយថវិកាចំនួន ២២ ៧១២.១លានរៀល។

## ៥.៣.៥. ថវិកាមត្តេយ្យសិក្សាសហគមន៍

មត្តេយ្យសិក្សាសហគមន៍ ជាកន្លែងដែលបង្កើតឡើង និងគាំទ្រដោយក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងមានក្រសួងពាក់ព័ន្ធមួយចំនួនចូលរួម សម្រាប់កុមារអាយុពី ៣ឆ្នាំ ដល់៥ឆ្នាំ អាចរហូតដល់ ៦ឆ្នាំ រួមទាំងជាចំណែកក្នុងការជួយកុមារនៅតំបន់ជនបទដាច់ស្រយាលអាចទទួលបានសេវាថែទាំ និងអប់រំប្រកបដោយនិរន្តរភាព។




*រូបភាពទី 17 ថវិកាមត្តេយ្យសិក្សាសហគមន៍ឆ្នាំ២០២៣-២០២៤*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

សម្រាប់ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានបង្កើនមត្តេយ្យសិក្សាសហគមន៍ចំនួន១៣៣ថ្នាក់ លើចំនួនមានស្រាប់១ ៣០៥ថ្នាក់សម្រាប់ឆ្នាំ២០២៣ ដូចនេះសរុបឆ្នាំ២០២៤ ចំនួន ១ ៤៣៨ថ្នាក់ ត្រូវចំណាយថវិកាចំនួន ១៤ ០០៦.១លានរៀល។

## ៥.៣.៦. ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ




*រូបភាពទី 18 លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ៦ វិច្ឆិកា ២០២៣*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

យោងតាមសេចក្តីប្រកាសព័ត៌មានលេខ ១៧ អយក.សប្រព ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង ០៦ វិច្ឆិកា ២០២៣ បានឱ្យដឹងថា បេក្ខជនប្រឡងជាប់សរុប ៩៨ ៤៦០ នាក់ ត្រូវជា ៧២.៨៩ ភាគរយនៃចំនួន បេក្ខជនមកប្រឡង។ បេក្ខជនជាប់និទ្ទេស A ចំនួន ១ ៦៧៣ នាក់, និទ្ទេស B ចំនួន ៦ ៩៦៤ នាក់, និទ្ទេស C ចំនួន ១៨ ៣០៨ នាក់, និទ្ទេស D ចំនួន ៣៤ ២៤៦ នាក់, និង និទ្ទេស E ចំនួន ៣៧ ២៦៩ នាក់។

សម្រាប់ឆ្នាំ២០២៤ ក្រសួងបានចំណាយថវិកាសម្រាប់រៀបចំកិច្ចដំណើរការ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ២៤ ៣១៩.៨លានរៀល។

## ៥.៣.៧. ការប្រកួតកីឡាស៊ីហ្គេមលើកទី៣២

ព្រឹត្តិការណ៍ស៊ីហ្គេមដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ បានរៀបចំពិធីបើកការប្រកួតជាផ្លូវការ កាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ ក្រោយកម្ពុជា រង់ចាំអស់រយៈពេល ៦៤ឆ្នាំ ហើយព្រឹត្តិការណ៍នេះ បានធ្វើឱ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពិសេសពីសំណាក់ប្រជាជនកម្ពុជាទូទាំងប្រទេស។ ក្រសួងបានបញ្ជូនប្រតិភូកីឡាសរុបចំនួន ១ ២០២នាក់ មានចំនួន ៣៦ប្រភេទកីឡា វិញ្ញាសា ៥៤៥ ក្នុងចំណោម ៥៨០វិញ្ញាសា។ ការប្រកួតចាប់ផ្ដើមមុនថ្ងៃពិធីបើកកម្មវិធីមាន០៦ប្រភេទកីឡា បាល់ទាត់ អុកចត្រង្គ គ្រីកឃីត ហុកគីក្នុងសាល ទូកក្ដោង និងបាល់ទះក្នុងសាល ចាប់ផ្ដើមពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣។




*រូបភាពទី 19 ចំនួនមេដាយដែលកម្ពុជាទទួលបានក្នុងព្រឹត្តិការណ៍ស៊ីហ្គេមលើកទី ៣២ ឆ្នាំ២០២៣*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

កម្ពុជាបានបិទបញ្ចប់ព្រឹត្តិការណ៍ស៊ីហ្គេមលើកទី៣២ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ ជាមួយសមិទ្ធផលគួរជាទីមោទកហើយទទួលបានមេដាយក្នុងចំណាត់ថ្នាក់លេខ៤ សរុបចំនួន២៨២មេដាយ ក្នុងនោះមេដាយមាសចំនួន៨១ មេដាយប្រាក់ចំនួន៧៤ មេដាយសំរឹទ្ធចំនួន១២៧។

## ៥.៣.៨. ការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២

ព្រឹត្តិការណ៍អាស៊ានប៉ារ៉ាហ្គេមដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ បានរៀបចំពិធីបើកការប្រកួតជាផ្លូវការ នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៣ ហើយបានបញ្ជូនប្រតិភូកីឡាសរុបចំនួន៣៤៣នាក់ មានចំនួន១២ប្រភេទកីឡា វិញ្ញាសា២៦០ ក្នុងចំណោម៤៣៩វិញ្ញាសា។ មាន០១ប្រភេទកីឡា ចាប់ផ្តើមប្រកួតមុនថ្ងៃបើកកម្មវិធី បាល់បោះជិះរទេះ ចាប់ផ្តើមថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៣។




*រូបភាពទី 20 ចំនួនមេដាយដែលកម្ពុជាទទួលបានក្នុងព្រឹត្តិការណ៍អាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣*

*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

កម្ពុជាបានបិទបញ្ចប់ព្រឹត្តិការណ៍អាស៊ានប៉ារ៉ាហ្គេមលើកទី១២ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ ជាមួយសមិទ្ធផលគួរជាទីមោទកហើយទទួលបានមេដាយក្នុងចំណាត់ថ្នាក់លេខ៨ សរុបចំនួន៧៣មេដាយ ក្នុងនោះមេដាយមាសចំនួន៩ មេដាយប្រាក់ចំនួន១៩ មេដាយសំរឹទ្ធចំនួន៤៥។

## ៥.៣.៩. ការអភិវឌ្ឍយុវជន

ក្រសួងបានរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្រស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា ដោយបានសម្រិតសម្រាំង កម្មវិធីផ្តោតលើការអភិវឌ្ឍបំណិនរឹង និងបំណិនទន់សម្រាប់យុវជន ឆ្នាំសិក្សា២០២២-២០២៣ ក្រសួងបានបណ្តុះបណ្តាលបំណិនសតវត្សរ៍ទី២១ ដល់យុវជននិងកុមារ រួមមានបំណិនទន់ បំណិនត្រិះរិះពិចារណា ការធ្វើការងារជាក្រុម នវានុវត្តន៍ ការចេះតស៊ូអត់ធ្មត់ក្នុងការងារ ការដោះស្រាយបញ្ហា ភាពជាអ្នកដឹកនាំ បំណិនប្រាស្រ័យទាក់ទង ចំណេះដឹងភាសា ចំណេះដឹងឌីជីថល បំណិនសារព័ត៌មាន សហគ្រិនភាព ដើម្បីអភិវឌ្ឍយុវជនកម្ពុជាឱ្យក្លាយជា «ពលរដ្ឋល្អ» «ពលរដ្ឋសាកល» និង «មូលធនមនុស្ស» ដែលមានស្មារតីស្នេហាជាតិ មានការទទួលខុសត្រូវខ្ពស់ ចេះថ្លឹងថ្លែង និងផ្តល់តម្លៃចំពោះគុណបំណាច់ឥតគណនានៃសន្តិភាព និងការអភិវឌ្ឍសង្គមជាតិកម្ពុជា។




*រូបភាពទី 21 ចំនួនយុវជន និងកុមារទទួលបានបណ្តុះបណ្តាលបំណិនសតវត្សរ៍ទី២១ ឆ្នាំ២០២៣*

ក្រសួងបានលើកកម្ពស់បំណិនសតវត្សរ៍ទី២១ ដល់យុវជននិងកុមារ ១២ ២៣៣នាក់ ស្រី ៦ ៦៩៥នាក់ ពង្រឹងក្រុមប្រឹក្សាកុមារកម្ពុជា ៣៧៤ ៦៨៤ នាក់ ក្រុមប្រឹក្សាយុវជនកម្ពុជា ១ ៥៦៣ ២៩៤ នាក់ ជំរុញចលនាប្រឡងប្រណាំង ៣ល្អ «កូនល្អ សិស្សល្អ មិត្តល្អ» ទទួលបានពានរង្វាន់ផ្ញើមប្រចាំឆ្នាំដល់យុវជននិងកុមារ ៣១០នាក់ និងពង្រីកសមាជិកនៃកាយរឹទ្ធិជាតិកម្ពុជា ១៨០ ០០០នាក់ ស្រី ៤៨,៩៧ ភាគរយ នៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន និងសហគមន៍នានា ព្រមទាំងបានបង្កើតក្លិបសកម្មភាពយុវជន និងក្លិបសិក្សាដើម្បីជួយបំប៉នបន្ថែមដល់សិស្សត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

## ៦. សូចនាករសមិទ្ធកម្ម និងគោលដៅ

ដើម្បីវាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធីទាំង៥ខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានព្រមព្រៀងបង្កើតនិងអនុវត្តសូចនាករសមិទ្ធកម្មចំនួន ១៤ ដូចមានបញ្ជាក់ខាងក្រោម៖

| **គោលនយោបាយ/គោលបំណងកិច្ចព្រមព្រៀង** | **សូចនាករគន្លឹះ** | **គោលដៅ (លទ្ធផលក្នុងឆ្នាំ ២០២៤)** |
|---|---|---|
| **គោលបំណងកម្មវិធីទី១៖** ពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពសម្រាប់កុមារអាយុពី០ឆ្នាំ ទៅក្រោម៦ឆ្នាំ បង្កើនអត្រាបញ្ចប់ការសិក្សាសម្រាប់ការអប់រំចំណេះទូទៅនិងបង្កើនអត្រាអក្ខរកម្មជនពេញវ័យ | **សូចនាករទី១៖** ចំនួនសាលារៀនគំរូ | ២៥០ សាលា |
| | **សូចនាករទី២៖** ភាគរយសិស្សថ្នាក់ទី១២ ទទួលបាននិទ្ទេស A, B និង C | ២៣% |

| គោលនយោបាយ/គោលបំណងកិច្ចព្រមព្រៀង | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ ២០២៤) |
|---|---|---|
| **គោលបំណងកម្មវិធីទី២៖** ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឆ្លើយតបនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម | **សូចនាករទី១៖** អត្រារួមនៃការសិក្សានៅឧត្តមសិក្សា(១៨-២២ឆ្នាំ) | ១៨,៩០% |
| | **សូចនាករទី២៖** ចំនួននៃលទ្ធផលស្រាវជ្រាវដែលភ្ជាប់ជាមួយនឹងតម្រូវការទីផ្សារ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមដែលប្រើប្រាស់ដោយ HEIs និងឧស្សាហកម្ម | ២២ គម្រោងស្រាវជ្រាវ |
| **គោលបំណងកម្មវិធីទី៣៖** លើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា សំដៅលើសុខុមាលភាពប្រជាពលរដ្ឋ និងការប្រកួតកីឡាគ្រប់ប្រភេទឱ្យមានគុណផលកីឡា | **សូចនាករទី១៖** ចំនួនមេដាយបានពីការប្រកួតកីឡាអន្តរជាតិ | ១០៤ មេដាយ |
| | **សូចនាករទី២៖** ចំនួនសាលារៀនគំរូបានអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | ១៨០ សាលា |

| គោលនយោបាយ/គោលបំណងកិច្ចព្រមព្រៀង | សូចនាករគន្លឹះ | គោលដៅ (លទ្ធផលក្នុងឆ្នាំ ២០២៤) |
|---|---|---|
| **គោលបំណងកម្មវិធីទី៤៖** អនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និង ឆ្លើយតបតាមតម្រូវការចាំបាច់របស់យុវជន | **សូចនាករទី១៖** ចំនួនកុមារ និងយុវជនបានបញ្ចប់កម្មវិធីសមមូលការអប់រំមូលដ្ឋាន | ៨៥៩ នាក់ |
| | **សូចនាករទី២៖** ចំនួនយុវជន និងមនុស្សពេញវ័យបានបញ្ចប់ពីកម្មវិធីអភិវឌ្ឍន៍យុវជន និងមនុស្សពេញវ័យ (សាលារៀនគំរូ និង មជ្ឈមណ្ឌលគោលដៅ) | ១ ៨២០ នាក់ |
| **គោលបំណងកម្មវិធីទី៥៖** ពង្រឹងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល ការងារវិមជ្ឈការនិងវិសហមជ្ឈការ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន | **សូចនាករទី១៖** ភាគរយនៃការទូទាត់ចំណាយថវិកាកម្មវិធីរបស់ក្រសួងអប់រំ យុវជន និងកីឡា | ៩៥% |
| | **សូចនាករទី២៖** ចំនួនសាលារៀនដែលបានអនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រង | ២៥០ សាលា |
| | **សូចនាករទី៣៖** ចំនួនអ្នកឯកទេសអប់រំបានបណ្តុះបណ្តាលនិងទទួលស្គាល់ | ៦៤ នាក់ |

## ៧. ឯកសារយោង

1. ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៨-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា
2. ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤
3. ប្រកាសអន្តរក្រសួងលេខ ៩១១ សហវ.ប្រក.អថ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០២៣ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
4. គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ
5. លិខិតលេខ៣៤ អនក្រ.បក ចុះនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រនៅបឋមសិក្សា និងមធ្យមសិក្សាចំណេះទូទៅ
6. សេចក្តីប្រកាសព័ត៌មានលេខ ១៧ អយក.សប្រព ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖ ០៦ វិច្ឆិកា ២០២៣
7. ប្រកាសលេខ ៥៣៦ អយក.ប្រក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ជ័យលាភីក្នុងការប្រកួតកីឡាស៊ីហ្គេម លើកទី៣២ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
8. កិច្ចព្រមព្រៀងសមិទ្ធកម្មរវាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការអនុវត្តថវិកាសមិទ្ធកម្ម ឆ្នាំ២០២៤
9. ប្រកាសលេខ ៦៤៥ អយក.ប្រក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការទទួលស្គាល់ និងផ្តល់ប្រាក់រង្វាន់ជ័យលាភីក្នុងការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។